Khmer

# ស្ដីពីការលូតលាស់របស់កូនតើលោកអ្នកមានការបារម្ភអ្វីឬទេ?

## ～ចំពោះឪពុកម្ដាយឬអ្នកអាណាព្យាបាលដែលចិញ្ចឹមកូននៅជប៉ុន～

ពេលថ្មីៗនេះ ឪពុកម្ដាយឬអ្នកអាណាព្យាបាលដែលជាជនបរទេស ហើយដែលចិញ្ចឹមកូននៅប្រទេសជប៉ុនកើនកាន់តែច្រើនឡើងៗ។ ជាពិសេស
ក្នុងករណីដែលមានការបារម្ភចំពោះការលូតលាស់របស់កូន លោកអ្នកច្បាស់ជាមិនដឹងធ្វើយ៉ាងណាដើម្បីរកអ្នកពិគ្រោះ។
នៅតាមកន្លែងនីមួយៗទូទាំងប្រទេសជប៉ុន មានស្ថាប័ន(កន្លែង)ជាច្រើនដែលជួយឪពុកម្ដាយឬអ្នកអាណាព្យាបាលដែលមានការបារម្ភចំពោះការលូតលាស់របស់កូន។
យើងខ្ញុំមានមោទនភាពណាស់ បើសិនជាលោកអ្នកដែលជាឪពុកម្ដាយឬអ្នកអាណាព្យាបាលដែលជាជនបរទេស ប្រើកូនសៀវភៅនេះដើម្បីងាយស្រួលរកព័ត៌មាន ឬជំនួយចាំបាច់។

## ឧទាហរណ៍ តើធ្លាប់មានបញ្ហាបែបនេះឬទេ?

1. ការលូតលាស់នៃភាសាមានការយឺតយ៉ាវ។
2. ហៅឈ្មោះក៏មិនបែរមករកទេ។
3. មើលភ្នែកមិនចំ ឬពិបាកចំ។
4. ចាប់អារម្មណ៍ខ្លាំងជ្រុលទៅលើសម្លេង (បិទត្រចៀកខ្លួនឯង)។
5. គ្មានចំណាប់អារម្មណ៍ទៅលើកូនដទៃទេ។
6. ធ្វើចលនា មិននឹងនរ។
7. ចំណូលចិត្តមានការលំអៀង(ពណ៌ ពាណិជ្ជសញ្ញា សញ្ញា អក្សរ ឬលេខជាក់លាក់ណាមួយ ជាដើម)។
8. ពេលធ្វើអ្វីមួយជាមួយអ្នកផ្សេង មិនអាចធ្វើសកម្មភាពដូចគេដូចឯងទេ។
9. មានការពិបាកនឹងបង្រៀនឱ្យចេះរស់នៅ ដូចជាទៅបង្គន់ ឬផ្លាស់ខោអាវ ជាដើម។
10. ៗច្រើនតែមិនត្រូវចិត្ត មិនស្ងប់ចិត្ត។



ពេលដែលមានកូនមានបញ្ហាបែបនេះ មានការបារម្ភណាស់ .....
ងនេះ ប្រហែលជាបញ្ហាមួយរយៈពេលក៏មិនដឹងដែរ។ ឬក៏កូននោះមានបញ្ហាលូតលាស់
ជាពិសេស មានវិបត្តិក្នុងការលូតលាស់ក៏មិនដឹងដែរ។



## អ្វីទៅ វិបត្តិក្នុងការលូតលាស់ ?

"វិបត្តិក្នុងការលូតលាស់" គឺជាពិការភាពដែលពាក់ព័ន្ធនឹងការលូតលាស់នៃមុខងាររបស់ខួរក្បាល ហើយភាគច្រើន គឺជាពិការភាពពីកំណើត។ វិបត្តិក្នុងការលូតលាស់ មានច្រើនប្រភេទ ដូចរូបខាងក្រោមនេះ។ ទោះជាប្រភេទពិការភាពដូចគ្នាក៏ដោយ ក៏អាការៈវាខុសៗគ្នាទៅតាមម្នាក់ៗ។ លើសពីនេះ មានអ្នកខ្លះមានវិបត្តិក្នុងការលូតលាស់ច្រើនប្រភេទក៏មានដែរ។

អាចមានករណីបញ្ហាលូតលាស់យឺតយ៉ាវក៏មានដែរ

**វិបត្តិក្នុងការលូតលាស់ដែលកើតមានច្រើន**
**(Autism Spectrum Disorder: ASD)**
**អូទិស្សឹម** **Asperger's Syndrome**

- ការយឺតយ៉ាវនៃកាយលូតលាស់ខាងភាសា (ចំពោះជម្ងឺ Asperger's syndrome មិនមានការយឺតយ៉ាវខាងភាសាទេ)
- ពិបាកប្រាស្រ័យទាក់ទង
- មានបញ្ហាក្នុងការទំនាក់ទំនងនឹងមនុស្ស ឬសង្គម
- សកម្មភាពមានលំនាំដដែលៗ ចំណង់ចិត្តមានការលំអៀង ឬគិតជ្រុល
- អារម្មណ៍រសើបខ្លាំង ឬមិនមានអារម្មណ៍ មិនប៉ិនប្រសប់

**Attention Deficit Hyperactivity Disorder AD/HD**
**(ជម្ងឺកង្វះការយកចិត្តទុកដាក់-មិនអាចផ្ដោតអារម្មណ៍ ពិការភាពកង្វះការយកចិត្តទុកដាក់-មិនអាចផ្ដោតអារម្មណ៍)**

- មិនអាចផ្ដោតអារម្មណ៍ពបាន
- មិនអាចនៅស្ងៀមបាន
- ធ្វើសកម្មភាពមិនព្រៀងទុក

**វិបត្តិក្នុងការសិក្សា LD**
**(Localized learning disorder, Localized learning disability)**

- មិនមែនបញ្ហាលូតលាស់យឺតទាំងស្រុងទេ។ ក៏ប៉ុន្តែ "ការអាន" ឬ "ការសរសេរ" ឬ "ការគិតលេខ" អាចលូតលាស់យឺត។

※ក្រៅពីនេះ មាន Gilles De La Tourette Syndrome, ជម្ងឺនិយាយមិនច្បាស់,
ពិការភាពក្នុងការធ្វើចលនាសហការគ្នាដោយសារការលូតលាស់ ជាដើម ក៏ត្រូវបានចំណាត់ថាជា វិបត្តិក្នុងការលូតលាស់ដែរ។

## សូមទៅទទួលការពិនិត្យសុខភាពនៅសាលាស្រុក ឃុំ ភូមិ

នៅសាលាស្រុក ឃុំ ភូមិ គេមានធ្វើការពិនិត្យសុខភាពទារកដោយមិនយកកម្រៃ។
ការពិនិត្យសុខភាពនេះ គឺជាឱកាសមួយដ៏សំខាន់ ដើម្បីធ្វើការបញ្ជាក់អំពីស្ថានភាពសុខភាព
និងការលូតលាស់របស់កូនលោកអ្នក។ សូមទៅទទួលការពិនិត្យជាមិនខាន ។

- គ្រូពេទ្យធ្វើការពិនិត្យ។
- កម្លុងពេលពិនិត្យសុខភាពនេះ ខុសៗគ្នាទៅតាមរដ្ឋបាលមូលដ្ឋាននីមួយៗ។ អាស្រ័យហេតុនេះ សូមទាក់ទងនឹងរដ្ឋបាលមូលដ្ឋាន។
- ការពិនិត្យសុខភាពនីមួយៗ ត្រូវបានកំណត់ទៅតាមអាយុ។

**【ការពិនិត្យសុខភាពទារកកំពុងបំបៅ】**
ពេលដែលកូនមានអាយុ 3 ទៅ 4ខែ។ អាចពិគ្រោះអំពីការបារម្ភរបស់ខ្លួន នឹងការីសុខាភិបាលបាន។
ការីអាហារូបត្ថម្ភនឹងបង្រៀនអំពីរបៀបបញ្ចប់ការបំបៅកូន។

**【ការពិនិត្យសុខភាពកូនអាយុ 1ឆ្នាំកន្លះ】**
កូនដែលមានអាយុពី1ឆ្នាំកន្លះ ដល់មុនអាយុ 2ឆ្នាំ។ អាចពិគ្រោះអំពីការបារម្ភរបស់ខ្លួននឹងការីសុខាភិបាល។

**【ការពិនិត្យសុខភាពកូនអាយុ 3ឆ្នាំ】**
កូនដែលមានអាយុពី 3ឆ្នាំ ដល់មុនអាយុ 4ឆ្នាំ។ ពិនិត្យទឹកនោម។ ពិនិត្យភ្នែក និងត្រចៀក។
អាចពិគ្រោះអំពីការបារម្ភរបស់ខ្លួននឹងការីសុខាភិបាលការីអាហារូបត្ថម្ភ ការីចិត្តសាស្ត្រ។

**【ការពិនិត្យសុខភាពមុនចូលសាលា】**
នៅខ្ទង់ខែ 9 នៃមួយឆ្នាំមុនពេលកូនចូលសាលាបឋមសិក្សា គណៈកម្មការអប់រំនៃស្រុក ឃុំ ភូមិ
នឹងផ្ញើសេចក្ដីជូនដំណឹង។ សូមទៅទទួលការពិនិត្យសុខភាពមុនចូលសាលា
នៅសាលាបឋមសិក្សាដែលកូនរបស់លោកអ្នកគ្រោងនឹងចូលរៀន។ ពិនិត្យភ្នែក និងត្រចៀក។
ពិនិត្យមើលប្រាជ្ញាសង្ខេបៗ។

**【ការពិគ្រោះអំពីការចូលសាលា】**
គណៈកម្មការអប់រំ និង មជ្ឈមណ្ឌលអប់រំ ទទួលការពិគ្រោះអំពីកូនពិការ
ឬកូនដែលមានការបារម្ភអំពីជីវភាពរស់នៅតាមសាលាបឋមសិក្សា។
ការពិគ្រោះអំពីការចូលសាលា ត្រូវកក់ពេលវេលាទុកជាមុន។
ស្ដីពីការកក់ពេលវេលាសូមសួរទៅ គណៈកម្មការអប់រំ។

□ **ការអប់រំសម្រាប់កូនពិការ**
គណៈកម្មការអប់រំធ្វើការសម្រេចនូវកន្លែងដែលកុមារត្រូវទៅសិក្សាដោយគោរពទៅតាមឆន្ទៈរបស់ឪពុកម្ដាយ ឬកូនជាអតិបរមា។
នៅសាលាបឋមសិក្សា មាន "ថ្នាក់ជំនួយពិសេស" ឬ "ថ្នាក់ណែនាំកុមារពិការកម្រិតស្រាល"។
"សាលាជំនួយពិសេស" គឺជាសាលាសម្រាប់កុមារដែលពិការធ្ងន់។



## សូមទៅពិគ្រោះ

លក្ខណៈពិសេស និង ការលូតលាស់របស់កុមារម្នាក់ៗគឺផ្សេងៗគ្នា។ បើសិនជាមានការបារម្ភអ្វីមួយ សូមទៅពិគ្រោះឱ្យបានទាន់ពេលវេលា ដើម្បីចាត់វិធានការទៅតាមលក្ខណៈពិសេសរបស់កុមារម្នាក់ៗ គឺជាការសំខាន់។

- បើសិនជាមានការបារម្ភអំពីការចិញ្ចឹមកូន ឬអំពីការលូតលាស់របស់កូន ជាបឋម សូមទៅពិគ្រោះនឹងការិសុខាភិបាលនៃស្រុក ឃុំ ភូមិ។
- បើសិនជាកូនទៅទារកដ្ឋាន ឬសាលាមត្តេយ្យ សូមពិគ្រោះនឹងគ្រូនៅសាលានោះជាប្រចាំ។
- នៅតាមស្រុក ឃុំ ភូមិខ្លះ គេទទួលការពិគ្រោះពិសេសដោយអ្នកពិគ្រោះអំពីការលូតលាស់របស់កុមារ ឬការពិគ្រោះចល័តក៏មានដែរ។
- នៅស្រុក ឃុំ ភូមិខ្លះ គេមានថ្នាក់ជំនួយសម្រាប់ឱ្យកូននិងឪពុកម្ដាយទៅជាមួយគ្នាក៏មានដែរ។ ដូច្នេះ លោកអ្នកអាចពាក់ព័ន្ធផ្ទាល់នឹងការអប់រំស្របទៅតាមការលូតលាស់របស់កូនបាន។



※អ្នកទទួលការពិគ្រោះ កន្លែងទទួលការពិគ្រោះ គឺខុសៗគ្នាទៅតាមរដ្ឋបាលមូលដ្ឋាននីមួយៗ ។ ព័ត៌មានលំអិត សូមសួរការិសុខាភិបាល។

## ស្ដីពីមន្ទីរពេទ្យ



ការពិនិត្យអំពីវិបត្តិក្នុងការលូតលាស់ ត្រូវធ្វើដោយគ្រូពេទ្យជំនាញ (គ្រូពេទ្យកុមារ, គ្រូពេទ្យជម្ងឺផ្លូវចិត្តកុមារ)។ បើសិនជាចង់ឱ្យគេពិនិត្យ សូមត្រៀមដូចតទៅ។

- សូមស្វែងរកមន្ទីរពេទ្យដែលមានគ្រូពេទ្យជំនាញ។ សូមទៅពិគ្រោះនឹងការិសុខាភិបាល ឬមជ្ឈមណ្ឌលជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់តាមស្រុក ឃុំ ភូមិ (មន្ទីរពេទ្យភាគច្រើន ចាំបាច់កក់ជាមុន)។
- ពេលទៅទទួលការពិនិត្យលើកដំបូង សូមយកប័ណ្ណធានារ៉ាប់រងសុខភាព និង សៀវភៅសុខភាពម្ដាយនិងកូនតាមខ្លួនផង។
- សូមសរសេរទុកជាមុនអំពីអ្វីៗដែលជាការបារម្ភអំពីកូន និងស្ថានភាពនៅផ្ទះ ឬនៅទារកដ្ឋាន ជាដើម។



**<u>ការពិនិត្យ, វិធីព្យាបាលពិសេស</u>**

ប្រសិនបើមានភាពចាំពាច់ នៅមន្ទីរពេទ្យ បុគ្គលិកជំនាញនឹងធ្វើការពិនិត្យ ឬព្យាបាលពិសេស។ ការពិនិត្យ មានដូចជា ការពិនិត្យអំពីបញ្ញា និងការលូតលាស់, ការពិនិត្យត្រចៀក, ការពិនិត្យរលកខួរក្បាល ជាដើម។

**<u>បើសិនជាគ្រូពេទ្យថា កូនមានវិបត្តិក្នុងការលូតលាស់ ......</u>**

ពេលគ្រូពេទ្យថា កូនមានវិបត្តិក្នុងការលូតលាស់ លោកអ្នកច្បាស់ជាមានការបារម្ភខ្លាំងណាស់។ ក៏ប៉ុន្តែ តាមរយៈការរៀបចំបរិស្ថាន និងចាត់ចែងសមស្រប ស្ថានភាពរបស់កូនច្បាស់ជានឹងមានស្ថានភាពល្អបន្តិចម្ដងៗ។ ស្ដីពីរបៀបចាត់ចែង សូមពិគ្រោះនឹងគ្រូពេទ្យទទួលបន្ទុក ឬបុគ្គលិកជំនាញ។

## ស្ដីពីមជ្ឈមណ្ឌលជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់

**<u>ច្បាប់ស្ដីពីជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់</u>**

នៅជប៉ុន មាន "ច្បាប់ស្ដីពីជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់" ។ នេះគឺជាច្បាប់សម្រាប់ទ្រទ្រង់អ្នកមានវិបត្តិក្នុងការលូតលាស់ (ពីកូនក្មេង ដល់មនុស្សធំ) និងក្រុមគ្រួសារអ្នកនោះ។ ច្បាប់ស្ដីពីជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់មានគោលបំណងបង្កើតសង្គមមួយដែលអាចធ្វើឱ្យកូនដែលមានវិបត្តិក្នុងការលូតលាស់ អាចលូតលាស់ប្រកបដោយសុខភាពល្អ និងអាចឱ្យគ្រួសារកុមារនោះ គ្មានការបារម្ភក្នុងការចិញ្ចឹមកូន។

**<u>ស្ដីពីមជ្ឈមណ្ឌលជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់</u>**

ដើម្បីឱ្យអ្នកមានវិបត្តិក្នុងការលូតលាស់ឬក្រុមគ្រួសារអ្នកនោះអាចមានជីវភាពរស់នៅដោយគ្មានការបារម្ភនៅក្នុងសហគមន៍ មានស្ថាប័នជាច្រើន ដែលអាចពិគ្រោះបាន។ "មជ្ឈមណ្ឌលជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់ មានតួនាទីដ៏សំខាន់ក្នុងការជួយនៅតាមរាជធានីនិងខេត្តនីមួយៗ។ មជ្ឈមណ្ឌលត្រូវបានបង្កើតឡើង នៅគ្រប់រាជធានីនិងខេត្ត ព្រមទាំងក្រុងដែលកំណត់ដោយក្រឹត្យ។ ព័ត៌មានស្ដីពីមជ្ឈមណ្ឌលជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់ទូទាំងប្រទេស មាននៅក្នុងគេហទំព័រខាងក្រោមនេះ។

**មជ្ឈមណ្ឌលព័ត៌មាននិងជំនួយសម្រាប់អ្នកមានវិបត្តិក្នុងការលូតលាស់**

**http://www.rehab.go.jp/ddis/**

**[មជ្ឈមណ្ឌលជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់នៃតំបន់លំនៅដ្ឋានរបស់លោកអ្នក]**

**ឈ្មោះមជ្ឈមណ្ឌល :**

**លេខទូរស័ព្ទសម្រាប់ទំនាក់ទំនង :**

## ស្ដីពីសៀវភៅជនពិការ

បើសិនជាមានសៀវភៅបញ្ជាក់ថា មានពិការភាព (សៀវភៅជនពិការ) យើងអាចទទួលសេវាកម្មសុខុមាលភាពផ្សេងៗ ទៅតាមប្រភេទ និងកម្រិតនៃពិការភាព (ប្រាក់ឧបត្ថម្ភ ជាដើម)។ អ្នកដែលចង់បានសៀវភៅនេះ សូមទៅបំពេញបែបបទនៅសាលាស្រុក ឃុំ ភូមិ។

សៀវភៅនេះ មាន 3ប្រភេទ គឺ "សៀវភៅព្យាបាលថែទាំ" "សៀវភៅសុខភាព និងសុខុមាលភាពសម្រាប់ជនពិការផ្លូវចិត្ត" និង"សៀវភៅជនពិការរូបកាយ"។




- □ ពេលមានសៀវភៅនេះ នឹងមានការងាយស្រួលក្នុងការបំពេញបែបបទទទួលសេវាកម្មសុខុមាលភាព។
- □ <u>ទឹកប្រាក់ឧបត្ថម្ភ គឺខុសៗគ្នាទៅតាមប្រភេទ និងកម្រិតនៃពិការភាព។</u>
- □ <u>អ្នកដែលជាមុខសញ្ញានៃការទទួល និងខ្លឹមសារនៃសេវាកម្ម ជាដើម អាចខុសគ្នាមួយភាគ ទៅតាមស្រុក ឃុំ ភូមិ។</u>

※ស្ដីពីខ្លឹមសារលំអិត សូមសួរតាមសាលាស្រុក ឃុំ ភូមិនៃលំនៅដ្ឋានរបស់លោកអ្នក។

## ព័ត៌មានយោង

**◆គេហទំព័រជំនួយជីវភាពរស់នៅសម្រាប់ជនបរទេស**

មានព័ត៌មានចាំបាច់សម្រាប់ការរស់នៅៗជប៉ុនរបស់លោកអ្នក។ ក្រៅពីនេះ ក៏អាចស្វែងរកកន្លែងពិគ្រោះក្នុងតំបន់ដែរ។

http://www.moj.go.jp/isa/support/portal/index.html

**◆សេវាកម្មព័ត៌មានតាមរយៈការពិគ្រោះតាមទូរស័ព្ទមជ្ឈមណ្ឌលព័ត៌មានវិស័យពេទ្យអន្តរជាតិ AMDA**

មានការណែនាំឱ្យស្គាល់ស្ថាប័នព្យាបាលដែលអាចប្រើភាសាកំណើតរបស់លោកអ្នក ហើយក៏មានសេវាកម្មណែនាំអំពីរបបសុខុមាលភាពវេជ្ជសាស្ត្រ។

លេខាធិការដ្ឋានការិយាល័យតូក្យូ ទូរស័ព្ទ: 03-6233-9266

https://www.amdamedicalcenter.com/activities

**◆បកប្រែដោយ Google Translate [អភិវឌ្ឍដោយ : google,Inc]**

មាន Apps សម្រាប់បកប្រែឯកសារ, បកប្រែដោយប្រើកាមេរ៉ា, បកប្រែតាមការសរសេរដៃ, បកប្រែតាមសម្លេង។ សុទ្ធតែដោនឡូដបាន ហើយប្រើដោយឥតគិតថ្លៃ។




**◆Apps បកប្រែតាមសម្លេងពហុភាសា VoiceTra [អភិវឌ្ឍដោយ : NICT(នីតិបុគ្គលស្រាវជ្រាវ និងអភិវឌ្ឍជាតិ ទីភ្នាក់ងារស្រាវជ្រាវព័ត៌មាន និងទូរគមនាគមន៍)]**

គឺជា Apps ដែលបកប្រែជាសម្លេង នៅពេលដែលលោកអ្នកនិយាយភាសាបរទេសទៅកាន់ម៉ាស៊ីនដែលមាន Apss នោះ។ Appsនេះអាចបកប្រែ 31 ភាសា ហើយអាចដោនឡូដ ហើយប្រើដោយឥតគិតថ្លៃ។

http://voicetra.nict.go.jp/en/index.html

**◆សូមស្វាគមន៍លោកអ្នកដែលបានចូលដល់ CLARINET**

**គេហទំព័រព័ត៌មានស្ដីពីការអប់រំទូទៅតាមសាលា [ក្រសួងអប់រំ និងវិទ្យាសាស្ត្រ]**

គឺជាគេហទំព័រពាក់ព័ន្ធនឹងការអប់រំក្មេងរស់នៅបរទេស កុមារត្រឡប់មកជប៉ុនវិញ និងកុមារបរទេស ជាដើម។

http://www.mext.go.jp/a_menu/shotou/clarinet/003.htm

**◆មជ្ឈមណ្ឌលជម្រុញការអប់រំអ្នកមានវិបត្តិក្នុងការលូតលាស់**

អាចរកមើលវិធីទ្រទ្រង់ និងណែនាំកូនដែលមានវិបត្តិក្នុងការលូតលាស់ ឯកសារស្រាវជ្រាវ សម្ភារៈសិក្សា ឬឧបករណ៍សម្ភារៈជំនួយពាក់ព័ន្ធនឹងកូនដែលមានវិបត្តិក្នុងការលូតលាស់បាន។

http://icedd_new.nise.go.jp/

**[បោះពុម្ពផ្សាយដោយ]**

**មជ្ឈមណ្ឌលព័ត៌មាននិងជំនួយសម្រាប់អ្នកមានវិបត្តិក្នុងការលូតលាស់**

មជ្ឈមណ្ឌលជាតិស្ដារកាយនីតិសម្បទាជនពិការ ផ្នែកផែនការនិងព័ត៌មាន

**http://www.rehab.go.jp/ddis/**

មជ្ឈមណ្ឌលជាតិស្ដារកាយនីតិសម្បទាជនពិការ ផ្នែកផែនការនិងព័ត៌មាន
**មជ្ឈមណ្ឌលព័ត៌មាននិងជំនួយសម្រាប់អ្នកមានវិបត្តិក្នុងការលូតលាស់**

**[កាលបរិច្ឆេទនៃការបោះពុម្ពផ្សាយ]**
ខែមីនា ឆ្នាំ 2022